**សកម្មភាព** ៖ **ល្បែងធ្វើជារូបឥន្ទធនូ**

**ចិត្តចលភាព**

បំណិនចលកតូច (ការហ្វឹកហាត់បង្កើនកម្លាំង សម្របសម្រួលសាច់ដុំដៃ និងភ្នែកសាច់ដុំភ្នែក)។

**សិក្សាសង្គម**

គំនូរ និងសកម្មភាពកសាង (ការយល់ដឹង ការពេញចិត្តចំពោះសិល្បៈតាមរយៈការបង្កើតរូបភាព)។

**បុរេគណិត**

ទំហំ និងពណ៌ (ចំណាត់ក្រុម និងលំដាប់លំដោយ)។

**គោលបំណង** ៖

**(ចិត្តចលភាព)** ប្រាប់ពីររបៀបធ្វើចលនាដៃតាមទម្រង់ផ្សេងៗដោយការធ្វើអ្វីមួយ ឬលេងល្បែង។

**(សិក្សាសង្គម)** ការបង្ហាញពីរសកម្មភាពផ្សេងៗទៀតដែលបានបង្កើតជាស្នាដៃ។

**(គណិតវិទ្យា)** ប្រាប់បានពីរបៀបរៀបវត្ថុតាមលំដាប់ក្រុម ប្រភេទ ទំហំ និងពណ៌។

**កម្រិត** ៖ មធ្យម ទាប ខ្ពស់

**សៀវភៅ** ៖ ដកស្រង់ចេញពីរឿង “តើនរណាជាអ្នកលាបពណ៌មេឃ?” ។

**រយៈពេល** ៖ ៣០ នាទី

**ឧបករណ៍** ៖ ក្រដាសពណ៌ផ្សេងៗគ្នា ឬគម្របដបទឹក។

**ការរៀបចំ** ៖ កាត់ក្រដាសពណ៌ទៅជារាងតូចៗ ឬប្រមូលគម្របដបដែលមានពណ៌ផ្សេងៗគ្នា ។

**សេចក្តីណែនាំ៖**

1. ថ្ងៃនេះអ្នកគ្រូនឹងលេង**ល្បែងធ្វើជារូបឥន្ទធនូ**ជាមួយកូនៗតាំងអស់គ្នា។
2. សួរក្មេងៗថា៖ តើកូនៗស្គាល់ឥន្ទធនូដែរឬទេ? បាទ/ចាស ស្គាល់
3. តើឥន្ទធនូមានរាងយ៉ាងដូចម្តេច? មានរាងកោង រួចធ្វើដៃកោង ហើយក្មេងៗទាំងអស់គ្នាធ្វើតាម។
4. បង្ហាញក្រដាសពណ៌គ្រប់ពណ៌ ហើយឱ្យក្មេងៗថាតាម នឹងបង្ហាញគម្របដបទឹកផងដែរ។
5. ចែកក្រដាសពណ៌ ឬ គម្របដបទឹកទៅឱ្យក្មេងៗឱ្យបានគ្រប់គ្នា។
6. ត្រូវស្វែងរកក្មេងណាដែលមានពណ៌ក្រដាស ឬ គម្របដបដូចគ្នាដើម្បីបង្កើតជាក្រុម។
7. ក្រុមនីមួយៗត្រូវដាក់វេនគ្នាដាក់ក្រដាស់ពណ៌ ឬ គម្របពណ៌នៅលើដី ឬលើតុ កន្លែងណាក៏បាន ដើម្បីធ្វើជារូបឥន្ទធនូឱ្យបានត្រឹមត្រូវទៅតាមពណ៌របស់ឥន្ទធនូ។

**ការប្រែប្រួល៖**

សកម្មភាពនេះក៏អាចត្រូវបានប្រើជាសិល្បៈមួយ ដែលក្មេងៗត្រូវបានគេផ្តល់ក្រដាសតូចៗដើម្បីតម្រៀប បន្ទាប់មកប្រើការបិទលើក្រដាស ដើម្បីបង្កើតជាឥន្ទធនូ។